សម្រាប់ការចេញផ្សាយបន្ទាន់

គណៈកម្មការទន្លេមេគង្គ និងទីភ្នាក់ងារជប៉ុន សម្រាប់កិច្ចសហប្រតិបត្តិអន្តរជាតិ ប្រកាសចាប់ផ្តើមអនុវត្តការសិក្សារួមគ្នាស្តីពីការអភិរក្សព្រៃឈើ ក្នុងអាងទន្លេមេគង្គ ដើម្បីធ្វើឱ្យការគ្រប់គ្រងអាងទន្លេកាន់តែមានភាពប្រសើរជាងមុន

ទីក្រុងវៀងចន្ទ ប្រទេសឡាវ, ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៨ – គណៈកម្មការទន្លេមេគង្គ (MRC) និងទីភ្នាក់ងារជប៉ុនសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ (JICA) បានប្រកាសចាប់ផ្តើមអនុវត្តការសិក្សារួមគ្នាមួយលើការអភិរក្សព្រៃឈើ និងការគ្រប់គ្រងតំបន់អាងទន្លេ ក្នុងតំបន់ទន្លេមេគង្គខ្សែទឹកខាងក្រោម ដែលជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងរបស់ស្ថាប័នទាំងពីរ ក្នុងការធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រង និងការអភិរក្សបរិស្ថាន ក្នុងតំបន់អាងទន្លេនេះ។

សេចក្តីប្រកាសចាប់ផ្តើមអនុវត្តនេះ ត្រូវបានធ្វើឡើងនៅក្នុងកិច្ចប្រជុំផ្សព្វផ្សាយមួយ ដែលបានរៀបចំធ្វើឡើងនៅថ្ងៃនេះ ក្នុងទីក្រុងវៀងចន្ទ ដែល MRC និង JICA បានចុះហត្ថលេខាលើអនុសរណៈ ស្តីពីកិច្ចសហប្រតិបត្តិការសម្រាប់គម្រោង ជាមួយនឹងវត្តមានមន្ត្រីចំនួន ៤០ រូប មកពីស្ថាប័នទាំងពីរ។

ក្រោមហិរញ្ញប្បទានពីរដ្ឋាភិបាលជប៉ុន តាមរយៈ JICA គម្រោងនេះ នឹងគ្របដណ្តប់លើប្រទេសចំនួន ៥ ក្នុងតំបន់ទន្លេមេគង្គ ដូចជា កម្ពុជា ឡាវ ថៃ វៀតណាម និងមីយ៉ានម៉ា ហើយនឹងត្រូវបញ្ចប់នៅខែមីនា ឆ្នាំ ២០១៩។

លោក ផាំ ទាន់ផាន (Pham Tuan Phan) នាយកប្រតិបត្តិនៃលេខាធិការដ្ឋាន MRC បានមានប្រសាសន៍ថា "គម្រោងនេះ ផ្តល់លទ្ធភាពឱ្យយើងធ្វើការវាស់វែងស្ថានភាពបច្ចុប្បន្ននៃគម្រោងព្រៃឈើ និងការអភិរក្សព្រៃឈើ ក្នុងរដ្ឋ ជាសមាជិករបស់យើង និងក្នុងប្រទេសមីយ៉ានម៉ា និងចាត់វិធានការទប់ទល់ ដូចជា ការដាក់ចេញនូវអនុសាសន៍គោលនយោបាយ ដើម្បីបង្កើនគុណភាពនៃការគ្រប់គ្រងតំបន់អាងទន្លេទាំងមូល ដើម្បីបុព្វហេតុនៃការការពារព្រៃឈើ។"

រដ្ឋាភិបាលជប៉ុន គឺជាដៃគូអភិវឌ្ឍន៍មួយក្នុងចំណោមដៃគូអភិវឌ្ឍន៍ជាយូរមកហើយ របស់ MRC ដោយបានផ្តល់នូវការគាំទ្រហិរញ្ញវត្ថុយ៉ាងសកម្មដល់គណៈកម្មការនេះ ចាប់តាំងពីឆ្នាំ ២០០១ ក្នុងវិស័យជាច្រើន ដូចជា ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត ប្រព័ន្ធធារាសាស្ត្រ សុវត្ថិភាពនៃការធ្វើនាវាចរ ការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងបរិស្ថាន ជាដើម។

លោក ម៉ូរីតា តាកាហ៊ីរ៉ូ (Morita Takahiro) អគ្គនាយករងជាន់ខ្ពស់របស់ JICA មានប្រសាសន៍ថា "ជប៉ុនចូលរួមជាមួយ MRC ក្នុងបេសកកម្មដ៏មានសារៈសំខាន់ ដើម្បីធានាឱ្យមានតុល្យភាពរវាងការអភិវឌ្ឍ និងការអភិរក្សធម្មជាតិ សំដៅសម្រេចឱ្យបាននូវការអភិវឌ្ឍ ប្រកបដោយចីរភាពសម្រាប់តំបន់អាងទន្លេនេះ។ យើងនឹងប្រមូលផ្តុំចំណេះដឹង បច្ចេកវិទ្យា និងធនធានរបស់យើង ដើម្បីជួយដល់ MRC ក្នុងការស្វែងរកដំណោះស្រាយចំពោះបញ្ហាបរិស្ថាន ដែលអាងទន្លេមេគង្គកំពុងជួបប្រទះនៅពេលបច្ចុប្បន្ននេះ។"

គម្រោងនេះ គឺជាគំនិតផ្តួចផ្តើមរបស់នាយករដ្ឋមន្ត្រីជប៉ុន លោក ហ្ស៊ីន សូអាបេ ដែលបានបង្ហាញពីបំណងរបស់លោកក្នុងការចាប់ផ្តើមការសិក្សាមួយ ដើម្បីរួមចំណែកដល់ការអភិរក្សបរិស្ថាន ជាពិសេសការការពារធនធានព្រៃឈើក្នុងតំបន់អាងទន្លេមេគង្គ ដែលលោកបានលើកឡើងក្នុងកិច្ចប្រជុំកំពូល មេគង្គ-ជប៉ុន លើកទី ៨ នៅទីក្រុងវៀងចន្ទ កាលពីខែ កញ្ញា ឆ្នាំ ២០១៦។ ក្រុមជំនាញការរបស់ JICA បានធ្វើការងាររៀបចំគម្រោងនេះ តាំងពីពេលនោះមក។

នៅដើមឆ្នាំនេះ MRC ក៏បានប្រកាសចាប់ផ្តើមអនុវត្តគម្រោងរួមគ្នាចំនួន ២ រវាងប្រទេសកម្ពុជា និងប្រទេសឡាវ និងរវាងប្រទេសកម្ពុជា និងប្រទេសថៃ ដើម្បីធ្វើឱ្យកាន់តែប្រសើរឡើងនូវការគ្រប់គ្រងធនធាននៅក្នុងតំបន់អាងទន្លេមេគង្គ និងឆ្លើយតបចំពោះបញ្ហាទឹកជំនន់ និងបញ្ហាគ្រោះរាំងស្ងួត។ គម្រោងនេះ ផ្តោតការយកចិត្តទុកដាក់លើការរៀបចំផែនការអភិវឌ្ឍន៍ឆ្លងដែន សម្រាប់គ្រប់គ្រងធនធានទឹកក្នុងតំបន់ល្បាក់ខោន ដែលមានទីតាំងស្ថិតនៅចន្លោះប្រទេសកម្ពុជា និងប្រទេសឡាវ ព្រមទាំង ពិនិត្យតាមដានផលប៉ះពាល់បរិស្ថាន ដោយសារគម្រោងទំនប់វារីអគ្គីសនីដងសាហុង និងការវាយតម្លៃនិងរៀបចំផែនការរួមគ្នា សម្រាប់គ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត នៅតំបន់ព្រំដែន កម្ពុជា និងថៃ ដែលជាតំបន់ទទួលរងទឹកជំនន់ញឹកញាប់។

គម្រោងរួមគ្នាទាំងពីរនេះ បានទទួលថវិកាពីរដ្ឋាភិបាលអាល្លឺម៉ង់ តាមរយៈទីភ្នាក់ងារសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ) រហូតដល់ខែ មិនា ឆ្នាំ ២០១៩ ខណៈពេលដែលគម្រោង ៣ ផ្សេងទៀត ដែលត្រូវបានរៀបចំក្នុងរយៈពេលដូចគ្នានេះ នៅត្រូវការការគាំទ្រថវិកា។

កំណត់សម្គាល់សម្រាប់និពន្ធនាយក៖

គណៈកម្មការទន្លេមេគង្គ គឺជាស្ថាប័នអន្តររដ្ឋាភិបាល ដែលមានតួនាទីជំរុញលើកកម្ពស់កិច្ចពិគ្រោះយោបល់ និងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់នៅក្នុងតំបន់អាងទន្លេមេគង្គខ្សែទឹកខាងក្រោម ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៥ ផ្អែកទៅតាមកិច្ចព្រមព្រៀងទន្លេមេគង្គ រវាងប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម។ ស្ថាប័ននេះ បំពេញតួនាទីជាវេទិកាថ្នាក់តំបន់សម្រាប់ការទូតទឹក ក៏ដូចជា ជាមជ្ឈមណ្ឌលប្រមូលផ្តុំចំណេះដឹងអំពីការគ្រប់គ្រងធនធានទឹក ដើម្បីការអភិវឌ្ឍន៍តំបន់នេះ ប្រកបដោយចីរភាព។

-**ចប់**-

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

លោក មាស សុភក្ត្រ
មន្ត្រីទំនាក់ទំនងស្តីទីសម្រាប់អ្នកសារព័ត៌មាន
អ៊ីម៉ែល៖ sopheak@mrcmekong.org
ទូរសព្ទ៖ +856-21-263263, ភ្ជាប់បន្ត 4070
ទូរសព្ទដៃ៖ +856-20-77779168

###